# សេចក្តីប្រកាស
# មូលនិធិដាំដុះ សម្រាប់គម្រោង ឆ្នាំ២០២៥
## «កម្មវិធី / ផ្នែក មូលនិធិ»

**ព័ត៌មានសំខាន់ៗ**

| | |
|---|---|
| ឱកាស | មូលនិធិ «ដាំដុះ» សម្រាប់គម្រោង ឆ្នាំ២០២៥ |
| រចនាឡើងដើម្បី | ជួយគាំទ្រដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ |
| អ្នកចូលរួមសរុប | រហូតដល់  ៥ កន្លែង |
| គម្រោង & ពេល | គម្រោងនៅចន្លោះខែ មករា ដល់ខែ ធ្នូ ឆ្នាំ២០២៥ |
| កាលបរិច្ឆេទសំខាន់ៗ | ១. វេទិកាសំណួរចម្លើយនៅអង្គការសិល្បៈខ្មែរអមតៈ ដោយផ្ទាល់ និង រឺតាមរយៈ Zoom នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០២៤ វេលាម៉ោង៥:៣០ ដល់ម៉ោង ៧:០០<br>២. កាលបរិច្ឆេទសម្ភាស នៅចន្លោះថ្ងៃទី ១៦ ដល់ ១៨ ខែតុលា ឆ្នាំ២០២៤<br>៣. កាលបរិច្ឆេទផ្តល់ដំណឹងអំពីលទ្ធផល នៅចន្លោះថ្ងៃទី ២៩ ដល់ ៣១ ខែតុលា ឆ្នាំ២០២៤ |
| ជំនួយគាំទ្រ | រហូតដល់ ២៥០០ ដុល្លារអាមេរិក |
| ផុតកំណត់ទទួលពាក្យ | «ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០២៤» |

អង្គការសិល្បៈខ្មែរអមតៈមានសេចក្តីរីករាយ នឹងប្រកាសបើកមូលនិធិ «ដាំដុះ» សរុបរហូតដល់ «៥» កន្លែង ដល់សិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ ដើម្បីយកទៅអនុវត្តគម្រោងរបស់ខ្លួន។ មូលនេះត្រូវបានបង្កើតឡើងដើម្បីគាំទ្រសិល្បករ និងអ្នកបម្រើការងារក្នុងវិស័យសិល្បៈ និងវប្បធម៌ សម្រាប់គាំទ្រអ្នកដែលទើបចាប់ផ្តើមការងារក្នុងគំនិតផ្តួចផ្តើម ឬពិសោធន៍គម្រោងរបស់ខ្លួន។ ពួកគាត់អាចស្នើសុំមូលនិធិនេះដើម្បីគាំទ្រគម្រោងទាំងមូល ឬដំណាក់កាលណាមួយនៃគម្រោងរបស់ខ្លួន។ គម្រោងទាំងនោះដូចជា៖ អភិវឌ្ឍគម្រោងច្នៃប្រឌិតថ្មីៗ គម្រោងសិល្បៈសហគមន៍ គម្រោងស្រាវជ្រាវ តន្ត្រីដែលប្រឈមនឹងការបាត់បង់ គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា។

គោលបំណងរយៈពេលវែងនៃ មូលនិធិ គឺផ្តោតសំខាន់ជាពិសេសទៅលើ គំនិតច្នៃប្រឌិត និងភាពជាអ្នកដឹកនាំ។ មូលនិធិនេះបើកទូលាយចំពោះគ្រប់ទម្រង់សិល្បៈ លើកលែងតែការដំឡើងស្នាដៃសិល្បៈទស្សនីយភាព។

គម្រោងទាំងអស់ត្រូវកើតឡើងក្នុងឆ្នាំ ២០២៥ ចាប់ពី «ខែ មករា ដល់ ខែធ្នូ ឆ្នាំ២០២៥»។ កម្មវិធីនេះសម្របសម្រួល កញ្ញា សាយ តុលា អ៊ីមែល tola@cambodianlivingarts.org រឺលេខទូរសព្ទ ០៧៧ ៥៥ ៨៥ ៤៥។

**ព័ត៌មានលម្អិតបន្ថែមស្តីពី ៖**

១. គោលដៅមូលនិធិ

មូលនិធិ «ដាំដុះ» សម្រាប់គម្រោងបង្កើតឡើងដើម្បីគាំទ្រដល់៖

- គម្រោងថ្មី/គម្រោងសិល្បៈច្នៃប្រតិដ្ឋ លើកលែង រឺមិនរាប់បញ្ចូលគម្រោងសិល្បៈទស្សនីយភាព
- គម្រោងសិល្បៈសហគមន៍
- គម្រោងស្រាវជ្រាវទាក់ទងទៅនឹងសិល្បៈវប្បធម៌កម្ពុជា

២. អត្ថប្រយោជន៍របស់មូលនិធិ

ទទួលបានប្រាក់ឧបត្ថម្ភ ឬ ប្រាក់រង្វាន់រហូតដល់ ២៥០០ ដុល្លារអាមេរិក។
(សម្គាល់៖ មូលនិធិភាគច្រើនទទួលបានប្រាក់ឧបត្ថម្ភពីចន្លោះ ១៥០០ - ២០០០ ដុល្លារអាមេរិក)

៣. អ្នកចូលរួមគោលដៅរបស់មូលនិធិ

- សិល្បករ និងអ្នកជំនាញផ្នែកសិល្បៈ និងវប្បធម៌
- អ្នកស្រាវជ្រាវ និស្សិត អ្នកនិពន្ធ និង អ្នកធ្វើវិវេចនា
- សមាជិកក្នុងសហគមន៍

**លក្ខខណ្ឌជ្រើសរើស៖**

ត្រូវតែជាពាក្យស្នើសុំរបស់អង្គការសិល្បៈខ្មែរអមតៈ។ សូមភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធដូចដែលបានតម្រូវឱ្យមាន។ ពាក្យស្នើសុំអាចជាភាសាខ្មែរ ឬអង់គ្លេស ឬចតចម្លើយជាវីដេអូ វីសំឡេងក៏បាន។

១. ពាក្យស្នើសុំ អាចបំពេញដោយដៃ ឬដោយកុំព្យូទ័រ។ ប្រសិនបើបេក្ខជនមានការលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០៧៧ ៥៥ ៨៥ ៤៥ ។

២. អាចធ្វើឡើងដោយបុគ្គលម្នាក់ ឬជាក្រុម។ ក្នុងករណីជាក្រុម ត្រូវបញ្ជាក់ឈ្មោះតែប្រធានក្រុម ឬអ្នកតំណាងក្រុម។

៣. ត្រូវបង្ហាញពី៖
- ការប្តេជ្ញាចិត្តក្នុងការអនុវត្តគម្រោងរបស់ខ្លួន
- ចំណាប់អារម្មណ៍ផ្ទាល់ខ្លួន, ប្រវត្តិនៃការអប់រំ និងការងារក្នុងវិស័យសិល្បៈ និងវប្បធម៌
- ចក្ខុវិស័យនៃគម្រោងរបស់ខ្លួន ថាតើវានឹងជួយដល់ការអភិវឌ្ឍវិស័យសិល្បៈវប្បធម៌ដោយរបៀបណា។

៤.មូលនិធិនេះ សម្រាប់អ្នកដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិកម្ពុជា លិខិតឆ្លងដែន ឬទិដ្ឋាការ K Visa។[1]

សិល្បៈខ្មែរអមតៈ ប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីអាយុ ពិការភាព ជនជាតិដើមភាគតិច ភេទ អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា និងសង្គមសេដ្ឋកិច្ចឡើយ។

*យើងសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ ដែលមានសំឡេង ហើយយើងនឹងផ្តល់ការគាំទ្រ (អាស្រ័យលើតម្រូវការ និងភាពចាំបាច់) ទៅដល់បេក្ខជនដែលទទួលបានជោគជ័យ។ ពួកយើងចង់គាំទ្រ ដល់អ្នកដែលមិនធ្លាប់ទទួលបានឱកាសបែបនេះពីមុនមក។*

៥. គម្រោងនិងពេលរបស់មូលនិធិ
- គម្រោងត្រូវអនុវត្តគម្រោងនៅចន្លោះខែមករា ដល់ខែធ្នូ ឆ្នាំ២០២៥

៦. ក្រុមពាក់ព័ន្ធនឹងមូលនិធិ
១. កញ្ញា យ៉ុន សុខខន នាយិកាគ្រប់គ្រងកម្មវិធី
២. កញ្ញា សាយ តុលា អ្នកសម្របសម្រួលកម្មវិធីមូលនិធិ

៧. ការសង្ខេបឡើងវិញអំពីកាលបរិច្ឆេទសំខាន់ៗ
១. វេទិកាសំណួរចម្លើយនៅអង្គការសិល្បៈខ្មែរអមតៈ ដោយផ្ទាល់ និង វីតាមរយៈ Zoom នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ ២០២៤ វេលាម៉ោង៥:៣០ ដល់ម៉ោង ៧:០០
២. កាលបរិច្ឆេទសម្ភាស នៅចន្លោះថ្ងៃទី ១៦ ដល់ ១៨ ខែតុលា ឆ្នាំ២០២៤
៣. កាលបរិច្ឆេទផ្តល់ដំណឹង នៅចន្លោះថ្ងៃទី ២៩ ដល់៣១ ខែតុលា ឆ្នាំ២០២៤

## លក្ខណសម្បត្តិត្រូវការ

ដើម្បីអាចចូលរួមកម្មវិធីបាន បេក្ខជនត្រូវ៖ សរសេរលក្ខណសម្បត្តិដែលត្រូវនឹងលក្ខខណ្ឌទាំងអស់នៅទីនេះ
- ត្រូវមានសញ្ជាតិខ្មែរ / កំពុងស្នាក់នៅប្រទេសកម្ពុជាកំឡុងពេលអនុវត្តគម្រោង
- មានពេលគ្រប់គ្រាន់សម្រាប់ចូលរួមកម្មវិធីតាមកាលបរិច្ឆេទទាំងអស់ដែលបានកំណត់ខាងលើ
- មានឆន្ទៈក្នុងការចូលរួមសហការ និងការតាំងចិត្តខ្ពស់ក្នុងការដឹកនាំ និងអនុវត្តគម្រោងមូលនិធិ ។

អាចរកបាននៅក្នុងឯកសារទិដ្ឋភាពទូទៅនៃមូលនិធិ ៖
របៀបដាក់ពាក្យ៖ សូមបំពេញព័ត៌មានរបស់អ្នក និងឆ្លើយសំណួរនៅក្នុងពាក្យស្នើសុំដែលអាចទាញយកតាមរយៈ

| |
|---|
| វគ្គសំណួរនិងចម្លើយ<br><br>ពួកយើងនឹងបើកវេទិកាសំណួរចម្លើយតាមអនឡាញ និងជួបផ្ទាល់ដែលលោកអ្នកនឹងមានឱកាសជួបជាមួយនឹង «ក្រុមការងារអង្គការសិល្បៈអមតៈ» ដើម្បីពិភាក្សាជុំវិញមូលនិធិ និងដំណើរការ នៃការដាក់ពាក្យ។<br>កាលបរិច្ឆេទ៖ «០៦ ខែកញ្ញា ២០២៣» ម៉ោង: «៥:៣០ ល្ងាច ដល់ម៉ោង ៧:០០ យប់» |

[1] បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ មិនអាចដាក់ពាក្យស្នើសុំមូលនិធិនេះទេ។

រឺចូលរួមតាមតំណភ្ជាប់ខាងក្រោម៖
តំណភ្ជាប់: https://us02web.zoom.us/j/8127047219?omn=84223261798 Meeting ID: 812 704 7219

អ្នកអាចដាក់ពាក្យស្នើសុំតាមរយៈអ៊ីមែល tola@cambodianlivingarts.org រឺលេខទូរសព្ទ័ ០៧៧ ៥៥ ៨៥ ៤៥ ត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ១១:៥៩ យប់។